ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ២៥៣ "ក១"
-ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៨០ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ ២៩៩៤ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ៣៧៤៦ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ០៨ និង ០០ នាទីព្រឹក នៅសាលសវនាការទី២ ជាន់ផ្ទាល់ដី ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៨០ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] **សូលីដែត** ភេទស្រី កើតថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៣ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] ម៉ាន (រ) ម្ដាយឈ្មោះ [redacted] លាងហុង (ស) ប្ដីឈ្មោះ [redacted] សុខជា (រ) មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។

-ជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី២(មព២) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៧៧ "ម"ដ.ឃ.ដ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ ។

ជាប់ចោទពីបទ: **ឆបោក** ប្រព្រឹត្តនៅចំណុចផ្ទះលេខ២៤បេ(បុរីសូនី) ផ្លូវលេខ៩៩ ភូមិឬស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២១ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

លោកមេធាវី [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ ២៤៣ ផ្លូវលេខ១៨២ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សូលីដែត។

លោកមេធាវី [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ២៤៣ ផ្លូវលេខ១៨២ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សូលីដែត។



Scanned with CamScanner

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុលីដា** អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ២៤បេ (បុរីសូនី) ផ្លូវលេខ៩៩ ភូមិឬស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ។

លោកមេធាវី [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ១៨៨ ផ្លូវE បុរីពិភពថ្មីឈូកមាស សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ វ៉ា សុលីដា។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ នៅចំណុចផ្ទះលេខ ២៤បេ (បុរីសូនី) ផ្លូវលេខ៩៩ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានករណី ឆបោក ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សូលីដែត ភេទស្រី អាយុ៣០ឆ្នាំ។កាលពីអំឡុងឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] សូលីដែត ដែលត្រូវជាប្អូនថ្លៃរបស់ឈ្មោះ [redacted] សុលីដា តែងតែនិយាយជំនឿខាងផ្លូវក្នុង និងបានប្រាប់ថាស្គាល់លោកសង្ឃនៅខេត្តតាកែវ ដែលអាចជួយកែប្រែវាសនាបាន តែតម្រូវឱ្យឈ្មោះ [redacted] សុលីដា ប្រគល់ប្រាក់មកឱ្យឈ្មោះ [redacted] សូលីដែត ដើម្បីរៀបចំពិធីផ្សេងៗ ដូចជាដាក់ប្រាក់ក្នុងស្រោមខ្នើយដេក និងដាក់តម្កល់លើជើងធូប ព្រមទាំងទិញមាសគីឡូចំនួន២ដុំ ដាក់ក្រោមឥដ្ឋការ៉ូក្នុងបន្ទប់។ ដោយមានការទុកចិត្តឈ្មោះ [redacted] សុលីដា បានប្រគល់ប្រាក់ជាបន្តបន្ទាប់ទៅឱ្យជនជាប់ចោទឈ្មោះ [redacted] សូលីដែត សរុបចំនួន ២៨៩,១៧៩ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួន) ដុល្លារអាមេរិក។ ក្រោយមកទើបឈ្មោះ [redacted] សុលីដា បានដឹងថាជនជាប់ចោទឈ្មោះ [redacted] សូលីដែត យកប្រាក់ដែលឈ្មោះ [redacted] សូលីដាប្រគល់ឱ្យនោះយកទៅធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន។ ចំណែកមាស២ដុំ ដែលឈ្មោះ [redacted] សូលីដា ដាក់ក្រមឥដ្ឋការ៉ូក៏ត្រូវបានត្រូវបានជនជាប់ចោទឈ្មោះ [redacted] សូលីដែត លួចប្ដូរដាក់មាសក្លែងក្លាយ និងយកមាសនោះទៅលក់បាត់ហើយ។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ឈ្មោះ [redacted] សុលីដា បានដាក់ពាក្យបណ្ដឹងទៅកងរាជអាវុធហត្ថរាជធានីភ្នំពេញ ហើយសមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សូលីដែត ដើម្បីធ្វើការសាកសួរ និងកសាងសំណុំរឿង រួចបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធី។

-បានឃើញ របាយការណ៍បញ្ជូនលេខ ២៣១/២០២៣ រ.ប.ក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣០៣៨ អ.យ.ឧ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៧៩ អ.យ.ឧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤៦១២ ម.ង.ង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សូលីដែត** បានឆ្លើយថា៖ ខ្លួនទទួលស្គាល់អង្គហេតុដូចការចោទប្រកាន់មែន។ ខ្លួនបាននិយាយបញ្ចុះបញ្ចូលបងថ្លៃដែលមានឈ្មោះ [redacted] សុលីដា អំពីរឿងទៅរកគ្រូដើម្បីឱ្យលើករាសីរកស៊ីមានបាន ដោយតម្រូវឱ្យជនរងគ្រោះដាក់ប្រាក់តំកល់ដើម្បីធ្វើពិធីប្រហែលចំនួនជាងម្ភៃម៉ឺនដុល្លារអាមេរិក។ មាសគីឡូ០២ដុំ ខ្លួនប្ដូរយកមាសក្លែងក្លាយទៅដាក់ចូលរីឯប្រាក់ដុល្លារក៏ខ្លួនដូរដាក់លុយក្លែងក្លាយដែរ។ ចំពោះរឿងអបិយជំនឿ ដើមបណ្ដឹងក៏មានការជឿជាក់ដែរ ព្រោះកន្លងមកក៏ទទួលបានលទ្ធផល ទើបជឿជាបន្តបន្ទាប់ ខ្លួនធ្វើកន្លងមកគឺមានការណែនាំពីបុគ្គលផ្សេងនៅពីក្រោយ ប៉ុន្តែមួយរយៈក្រោយមកខ្លួនទាក់ទងបុគ្គលនោះលែងបាន។ ខ្លួនទទួលស្គាល់ប្រាក់ដើមបណ្ដឹងតែចំនួនUSD២០០០០(ម្ភៃម៉ឺន)ដុល្លារអាមេរិក ប៉ុណ្ណោះ។

-ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុលីដា បានឆ្លើយថា ៖ កាលពីឆ្នាំ២០២០ ឈ្មោះ [redacted] សូលីដែត អាទស្រី អាយុ៣០ឆ្នាំ បានរៀបការជាមួយប្អូនប្រុសរបស់ខ្លួនឈ្មោះ [redacted] សុខជា ហើយបានមកស្នាក់នៅក្នុងផ្ទះជាមួយខ្លួនដែរ ស្ថិតនៅផ្ទះលេខ២៤បេ (បុរីសូនី) ផ្លូវ៩៩ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ប្រហែលជា២ខែទៅ៣ខែ ស្រាប់តែប្អូនថ្លៃឈ្មោះ [redacted] សូលីដែត និយាយថាខ្លួនជាមនុស្សអភ័ព្វ និងរកស៊ីមិនឡើង (អត់ផ្ទះបុង) ខ្លួនក៏ជឿដោយគិតថាជាញាតិ។ លុះក្រោយមកខ្លួនក៏យល់ព្រមធ្វើតាមសម្តីរបស់ឈ្មោះ [redacted] សូលីដែត ដែលបាននិយាយថា តម្កល់លុយជាមួយព្រះសង្ឃអង្គឈ្មោះ [redacted] រី ស្នាក់នៅវត្តព្រៃម្លូរ ខេត្តតាកែវ តែមិនឱ្យខ្លួនប្រគេនបច្ច័យទៅលោកបង(ព្រះសង្ឃឈ្មោះ [redacted] រី) ដោយផ្ទាល់នោះទេ គឺតម្រូវឱ្យខ្លួន បាញ់លុយទៅឈ្មោះ [redacted] សូលីដែត ហើយគាត់ថាអ្នកយកទៅប្រគេនបន្តជូនលោកបង។ ដោយសារតែជាប្អូនថ្លៃ ហើយពូកែនិយាយលួងលោម អូសទាញរហូតខ្លួនជឿងប់ លើសពីនេះឈ្មោះ [redacted] សូលីដែត និយាយថា លុយតម្កល់ទាំងនេះអាចដកវិញបាននៅពេលចប់ពិធី ដោយសារលឺដូច្នេះហើយទើបខ្លួន បានបាញ់លុយតាមរយៈគណនីABA ឈ្មោះ MORN SOLIDETH លេខ ០៨៦៤៤៤០៥៣ នឹងលេខ ០៧០៩៧៩៧២៦ ចាប់ពីឆ្នាំ២០២១ រហូតមកអស់ទឹកប្រាក់ជាងUSD ២០៧,៥៧៩ (ម្ភៃម៉ឺនប្រាំពីរពាន់ប្រាំរយចិតសិបប្រាំបួនដុល្លារអាមេរិក)។ ក្រោយពីទទួលបានប្រាក់ជាបន្តបន្ទាប់ឈ្មោះ [redacted] សូលីដែត បានប្រាប់ថា លោកបងឱ្យរៀបចំពិធីកប់មាស តម្កល់លុយចំនួនUSD ៣៤,៦០០ (បីម៉ឺនបួនពាន់ប្រាំមួយរយដុល្លារអាមេរិក) នៅក្រោមខ្នើយរបស់ឈ្មោះ [redacted] សូលីដែត ដើម្បីបើកហុងស៊ុយ រួចខ្លួនបានទៅទិញមាសចំនួនពីរដុំ ១ម្ភៃ ២០តម្លឹង អស់ប្រាក់USD ៤៧,០០០ (បួនម៉ឺនប្រាំពីរពាន់ដុល្លារអាមេរិក) និងកប់ដុំមាស នៅក្នុងបន្ទប់សមាធិ (បន្ទប់នេះមិនមានមនុស្សស្នាក់នៅទេ) ដោយធ្វើជាមួយឈ្មោះ [redacted] សូលីដែត។ ខ្លួនខូចខាតពេលវេលា និង ជិពាក់គេជុំទិស ហើយទឹកប្រាក់ដែលខ្លួនបាត់បង់ដោយឈ្មោះ [redacted] សូលីដែត បានយកទៅធ្វើជាប្រយោជន៍ ផ្ទាល់ខ្លួន មានចំនួនUSD ២៨៩,១៧៩ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លារអាមេរិក)។ កន្លងមក ខ្លួនតែងតែសុំឈប់ធ្វើកិច្ចនេះម្តងជាពីរដងដែរ ហើយទាមទារលុយត្រឡប់មកវិញ ប៉ុន្តែឈ្មោះ [redacted] សូលីដែត ចេះតែអូសទាញ និងបាននិយាយថា "បើ កូវ ឈប់កណ្តាលទី ដូចជាធ្វើបាបខ្លួន និងលោកបងចឹង" ទើបខ្លួន បន្តយកដី និងផ្ទះដាក់បញ្ចាំយកលុយឱ្យឈ្មោះ [redacted] សូលីដែត។ រហូតដល់អស់លទ្ធភាពសងគេ ខ្លួនទៅ កាយយកមាសនោះ ស្រាប់តែប្រែជាដុំមាសក្លែងក្លាយ ហើយលុយដែលតម្កល់ក្នុងខ្នើយ ក៏ក្លាយជាលុយដុល្លារ ក្រដាសសែនទៅវិញ ទើបនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ខ្លួនបានមកពាក្យបណ្តឹងនៅកងរាជអាវុធហត្ថរាជធានីភ្នំពេញ តែម្តង។

-ចម្លើយសាក្សីឈ្មោះ [redacted] សុខជា បានឆ្លើយថា ៖ខ្លួន និងឈ្មោះ [redacted] សូលីដែត ជាប្តីប្រពន្ធបានរៀបការតាំងពីឆ្នាំ២០២១មកម្ល៉េះ ជួនកាលមករស់នៅជាមួយម្តាយរបស់ខ្លួននៅក្នុងបុរីសូនីផ្ទះលេខ២៤ផ្លូវ៩៩ ភូមិឫស្សី១ សង្កាត់ស្ទឹងមាន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ហើយជួនកាលទៅរស់នៅជាមួយឪពុកចុងប្រពន្ធ នៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ចំពោះការងាររបស់ប្រពន្ធ និងបងស្រីឈ្មោះ [redacted] សុលីដា គឺខ្លួនមិនដឹងច្បាស់នោះទេ គ្រាន់តែដឹងត្រឹមថាពួកគាត់ទាំងពីរនាក់ទិញមាសយកមកធ្វើកិច្ចផ្លូវក្នុង ហើយចំពោះការផ្តល់លុយរបស់បងស្រីឱ្យទៅប្រពន្ធនោះខ្លួនមិនដឹងឡើយ។ លុះដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ បងស្រីបានប្រាប់ខ្លួនពីរឿងគាត់ដែលគាត់ធ្វើការងារជាមួយប្រពន្ធខ្លួន ហើយប្រាប់ខ្លួនទៀតថា ប្រពន្ធខ្លួនបានឆបោកលុយពីគាត់ច្រើនណាស់សម្រាប់យកទៅធ្វើការងារនោះ។បន្ទាប់មកខ្លួនបានសួរប្រពន្ធទើបគាត់ប្រាប់ថា ពិតជាបានទទួលលុយពីបងស្រីរបស់ខ្លួន ពិតប្រាកដមែន។



Scanned with
CamScanner

## សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុលីដា បានធ្វើសេចក្ដីសន្និដ្ឋានថាជនជាប់ចោទឈ្មោះ [redacted] សូលីដែត ពិតជាប្រព្រឹត្តអំពើ ឆបោក ជនរងគ្រោះឈ្មោះ [redacted] សុលីដា ខូចខាតប្រាក់អស់សរុបចំនួនUSD២៨៩,១៧៩ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លារអាមេរិក)ដោយជនជាប់ចោទប្រើល្បិចកលទុច្ចរិត លួងលោមជនរងគ្រោះប្រគល់ប្រាក់មកឱ្យដើម្បីរៀបចំធ្វើកិច្ចដំណើរផ្លូវក្នុង ដោយកូនក្ដីខ្លួនបានជឿទុកចិត្តលើជនជាប់ចោទ ទើបប្រគល់ប្រាក់ទៅឱ្យជនជាប់ចោទ។ហេតុនេះសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទ និងទាមទារសំណងខូចខាតចំនួនUSD២៨៩,១៧៩ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លារអាមេរិក) និងសំណងជម្ងឺចិត្ត ខូចខាតពេលវេលាចំនួនUSD ១០០ ០០០ (ដប់ម៉ឺនដុល្លារអាមេរិក) ។

## <u>សេចក្ដីសន្និដ្ឋានម្ដីងសុំរបស់តំណាងអយ្យការ</u>

-ក្រោយពីបានស្ដាប់ការសាកសួរដេញដោលរួចមកឃើញថា ជនជាប់ចោទពិតបានប្រព្រឹត្តអំពើ **ឆបោក** ដែលចម្លើយរបស់ជនជាប់ចោទ ,ដើមបណ្ដឹងរដ្ឋប្បវេណី ,ចម្លើយសាក្សី និងឯកសារភស្តុតាងមានភាពស៊ីសង្វាក់គ្នា ហេតុនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៧៩ អ.យខ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដដែល និងស្នើសុំទៅក្រុមជំនុំជម្រះផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សូលីដែត បានធ្វើសេចក្ដីសន្និដ្ឋានថា៖ យោងតាមការបកស្រាយនូវអង្គហេតុខាងលើ បានបញ្ជាក់ផងដែលថាចំពោះបទល្មើស **ឆបោក** ទៅលើជនរងគ្រោះឈ្មោះ [redacted] **សុលីដា** ដែលកូនក្ដីខ្លួនឈ្មោះ [redacted] **សូលីដែត** បានប្រព្រឹត្តនោះ កូនក្ដីខ្លួនក៏បានសហការផ្ដល់ចម្លើយនៅគ្រប់ដំណាក់ការទាំងអស់របស់តុលាការ។ ដោយហេតុថាកូនក្ដីខ្លួនមានជីវភាពខ្វះខាតយ៉ាងខ្លាំង ទើបកូនក្ដីខ្លួនបង្ខំចិត្តប្រព្រឹត្តនូវអំពើបែបនេះ ហើយកូនក្ដីខ្លួនក៏បានដឹងនូវកំហុសរបស់ខ្លួន ដោយមានការសោកស្ដាយយ៉ាងខ្លាំង ដែលខ្លួនបានប្រព្រឹត្តអំពើល្មើសនេះ ដោយខ្វះការយល់ដឹង និងមិនបានគិតពិចារណា។ ក៏ប៉ុន្តែ កូនក្ដីខ្លួនមិនយល់ស្រប តាមការលើកឡើងពីឈ្មោះ [redacted] **សុលីដា** ថាបានប្រគល់ប្រាក់ឱ្យមកកូនក្ដីខ្លួនចំនួន **២៨៩,១៧៩$** (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លាអាមេរិក) គឺមិនមានភាពត្រឹមត្រូវនោះទេ ដោយកូនក្ដីខ្លួនបានឆ្លើយបំភ្លឺនៅពេលសវនាការគឺបានអះអាងថាខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] **សុលីដា** ត្រឹមតែ ២០០,០០០$ (ម្ភៃម៉ឺនដុល្លាអាមេរិកអាមេរិក)តែប៉ុណ្ណោះ។ ដោយស្របទៅតាមមាត្រា ៣៧៧ បទឆបោក, មាត្រា ៩៣ និយមន័យនៃស្ថានសម្រាលទោស នៃក្រមព្រហ្មទណ្ឌរបស់ ព្រះរាជាណាចក្រកម្ពុជា។ដោយយោងទៅតាមអង្គហេតុ និងអង្គច្បាប់មានភាពស៊ីចង្វាក់គ្នា ដោយហេតុថាកូនក្ដីខ្លួនបានដឹងនូវកំហុសរបស់ខ្លួន ព្រមទាំងមានការសោកស្ដាយនូវទង្វើដែលខ្លួនបានប្រព្រឹត្ត។ បច្ចុប្បន្នស្ថានភាពគ្រួសាររបស់កូនក្ដីខ្លួនកំពុងជួបការលំបាក ដែលមានតួនាទីត្រូវប្រកបរបរចិញ្ចឹមគ្រួសារ ដោយមានកូនតូចនៅក្នុងបន្ទុកថែមទៀតផង។ ដូច្នេះខ្លួនសូមឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្ដីខ្លួនឈ្មោះ [redacted] **សូលីដែត** ដោយហេតុថាកូនក្ដីរបស់ខ្លួនពិតជាបាន ទទួលស្គាល់កំហុសរបស់ខ្លួន ហេតុនេះសូមតុលាការមេត្តាពិចារណា ចំពោះស្ថានសម្រាលទោសឱ្យកូនក្ដីខ្លួនក្នុងកម្រិតអប្បបរមានៃទោស តាមច្បាប់។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **សូលីដែត** បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសំណូមពរដល់តុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ខ្លួនដឹងពីកំហុសហើយ។

## តុលាការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.តុលាការបានទទួលបណ្តឹងជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៨០ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣ ដោយដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.តាមលទ្ធផលសវនាការ បានបង្ហាញថា:កាលពីអំឡុងឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ជនជាប់ចោទឈ្មោះ [redacted] សូលីដែត បានប្រើឧបាយកលទុច្ចរិតប្រព្រឹត្តអំពើ ឆបោក ជនរងគ្រោះឈ្មោះ [redacted] សុលីដា ជាបងថ្លៃដោយប្រើមធ្យោបាយជំនឿអរូបិយ ថាបងថ្លៃខ្លួនឈ្មោះ [redacted] សុលីដា មានជីវិតអភ័ព្វគួរ ខ្លួនបានស្គាល់លោកសង្ឃឯនៅខេត្តតាកែវ អាចកែប្រែវាសនាឲ្យបានដោយតម្រូវឲ្យជនរងគ្រោះប្រគល់ប្រាក់ទៅឲ្យខ្លួន ដើម្បីរៀបចំពីធីផ្សេងៗដូចជាដាក់ប្រាក់ក្នុងស្រោមខ្នើយកើយ ដាក់តម្កល់លើជើងធូប ឲ្យទិញមាសគីឡូ២ដុំដាក់ក្រោមឥដ្ឋការ៉ូក្នុងបន្ទប់។ជនរងគ្រោះឈ្មោះ [redacted] សុលីដា មានជំនឿចង់កែប្រែវាសនា និងមានទំនុកចិត្តលើជនជាប់ចោទជាប្អូនថ្លៃ បានប្រគល់ប្រាក់ជាបន្តបន្ទាប់ទៅជនជាប់ចោទឈ្មោះ [redacted] សុលីដែត សរុបចំនួន USD ២៨៩,១៧៤(ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួន)ដុល្លារអាមេរិក ។ ក្រោយមកទើបជនរងគ្រោះដឹងថាជនជាប់ចោទបានយកប្រាក់របស់ខ្លួនទៅប្រើប្រាស់ផ្ទាល់ខ្លួន ។ ចំពោះមាស០២ដុំដាក់ក្រោមឥដ្ឋការ៉ូជនជាប់ចោទបានប្តូរជាមាសក្លែងក្លាយដោយយកមាសសុទ្ធរបស់ជនរងគ្រោះ និងប្រាក់ដុល្លារដាក់ក្រោមជើងធូប ប្តូរដាក់លុយដុល្លារសែនជំនួសវិញ។

៣.ជនជាប់ចោទឈ្មោះ [redacted] សូលីដែត នៅតំណាក់កាលនៅចៅក្រមស៊ើបសួរ ឆ្លើយមិនទទួលស្គាល់ការចោទប្រកាន់ថាខ្លួន ឆបោក ជនរងគ្រោះឈ្មោះ [redacted] សុលីដា នោះទេ។ តែនាពេលសវនាការជនជាប់ចោទឈ្មោះ ម៉ន សូលីដែត បានឆ្លើយសារភាពទទួលស្គាល់ថា ខ្លួនបានប្រព្រឹត្តអំពើ ឆបោក ជនរងគ្រោះឈ្មោះ [redacted] សុលីដា ជាបងថ្លៃខ្លួនពិតមែនដោយមាសគីឡូ០២ដុំ ខ្លួនប្តូរយកមាសក្លែងក្លាយទៅដាក់ចូល រីឯប្រាក់ដុល្លារក៏ខ្លួនដូរដាក់លុយក្លែងក្លាយដែរ។ ខ្លួនធ្វើនោះតាមបញ្ជារបស់មនុស្សប្រុសម្នាក់ តែខ្លួនសុំមិនប្រាប់ឈ្មោះ ខ្លួនសុខចិត្តទទួលខ្លួនឯង។ លុយនិងមាសមិនបានយកទៅឲ្យលោកសង្ឃនៅខេត្តតាកែវនោះទេ គឺខ្លួននិយាយកុហកជនរងគ្រោះ។ចម្លើយសារភាពរបស់ជនជាប់ចោទនាពេលសវនាការតុលាការជឿបាន ពីព្រោះមានលក្ខណ:ស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សុលីដា មានភាពច្បាស់លាស់ដោយគ្មានវិមតិសង្ស័យនោះឡើយ។

៤.តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] សុលីដា ថា៖ឈ្មោះ [redacted] សូលីដែត ជាប្អូនថ្លៃខ្លួនរស់នៅផ្ទះជាមួយគ្នា។ឈ្មោះ [redacted] សូលីដែត បាននិយាយប្រាប់ខ្លួនថា ខ្លួនជាមនុស្សអភ័ព្វរកស៊ីមិនឡើងគ្មានផ្ទះបុណ្យ ខ្លួនក៏ជឿតាមព្រោះគិតថាជាសាច់ញាតិ ឈ្មោះ [redacted] សុលីដែត និយាយថាស្គាល់ព្រះសង្ឃមួយអង្គឈ្មោះ [redacted] រី នៅវត្តព្រៃម្លូរ ខេត្តតាកែវ។ឈ្មោះ [redacted] សូលីដែត ឲ្យខ្លួនបាញ់លុយទៅឲ្យដើម្បីគេយកលុយទៅប្រគេនព្រះសង្ឃផុងរី។មូលហេតុខ្លួនជឿតាមឈ្មោះ [redacted] សូលីដែត

ដោយសារគេជាប្អូនថ្លៃ គេនិយាយលួងលោមអូសទាញហើយថាលុយតំកល់ដកវិញបាននៅពេលចប់ពិធី។ខ្លួនបានបាញ់លុយឲ្យជនជាប់ចោទជាបន្តបន្ទាប់តាមABA ពីឆ្នាំ២០២១ រហូតអស់ប្រាក់ចំនួនUSD ២០៧, ៥៧៩ (ម្ភៃម៉ឺនប្រាំពីរពាន់ប្រាំរយចិតសិបប្រាំបួន)ដុល្លារអាមេរិក។បន្តបន្ទាប់ទៀតជនជាប់ចោទបានឲ្យខ្លួនរៀបចំពិធីកប់មាស និងតំកល់លុយចំនួន USD ៣៤,៦០០ (បីម៉ឺនបួនពាន់ប្រាំមួយរយ)ដុល្លារអាមេរិក នៅក្រោមខ្នើយរបស់ជនជាប់ចោទ ដើម្បីបើកហុងស៊ុយខ្លួនបានទិញមាស០២ដុំអស់ប្រាក់ចំនួនUSD ៤៧,០០០ (បួនម៉ឺនប្រាំពីរពាន់)ដុល្លារអាមេរិក លុយនិងមាសឲ្យកប់ក្នុងបន្ទប់សមាធិ ដែលបន្ទប់គ្មានមនុស្សនៅ។ ក្នុងមួយថ្ងៃជនជាប់ចោទឲ្យខ្លួនចូលសមាធិរយៈពេល០៣ម៉ោង។ ខ្លួនបានសុំឈប់ធ្វើពីរទៅបីដងដែរ ដោយទាមទារយកលុយមកវិញ តែជនជាប់ចោទមិនព្រមឲ្យឈប់។ ខ្លួនបានយកផ្ទះនិងដីទៅដាក់បញ្ចាំ ហើយខ្លួនអស់លទ្ធភាពសងគេ ទើបសុខចិត្តទៅកាយយកមាសក្លែងក្លាយ លុយតំកល់ក្រោមខ្នើយជាលុយក្រដាស់សែន។ ចុងក្រោយឈ្មោះ [redacted] ស្ងួលីដែត ទទួលស្គាល់ និងសុំសងលុយទាំងអស់វិញ តែការសន្យាម្តងហើយម្តងទៀត ទើបខ្លួនសម្រេចចិត្តដាក់ពាក្យបណ្តឹង។សរុបប្រាក់ដែលឈ្មោះ [redacted] ស្ងួលីដែត បោកយកអស់ចំនួន USD២៨៩,១៧៩(ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លារអាមេរិក)។ ចម្លើយជនរងគ្រោះអាចឲ្យតុលាការជឿបាន ពីព្រោះជនជាប់ចោទនាពេលសវនាការបានឆ្លើយទទួលស្គាល់ថាខ្លួនបាន បោកយកលុយរបស់ដើមបណ្តឹង ពិតមែន។

៥.តាមចម្លើយសារភាពរបស់ជនជាប់ចោទ, ចម្លើយជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី និងតាមរយៈភស្តុតាងឯកសារដែលជនរងគ្រោះបានបង្ហាញតុលាការ បានស្តែងឲ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ស្ងួលីដែត បានប្រើឧបាយកលទុច្ចរិត លួងលោមអូសទាញជនរងគ្រោះដោយប្រើឧបាយកលថាជនរងគ្រោះជាមនុស្សអភ័ព្វគួ អស់ផ្ទះបុណ្យ ជាអបិយជំនឿ ហើយបន្លំយកទ្រព្យរបស់ជនរងគ្រោះ នាំឲ្យជនរងគ្រោះខូចប្រយោជន៍បាត់បង់ប្រាក់ជាច្រើន ដោយសារតែជឿពាក្យសំដីបោកបញ្ឆោតរបស់ជនជាប់ចោទឈ្មោះ [redacted] ស្ងួលីដែត មានធាតុផ្សំជាបទល្មើស ឆបោក ដែលមានបញ្ញត្តិក្នុងមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ ពិតមែន។

៦.អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបៀបរៀបរយសង្គមដែលច្បាប់បានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសតាមច្បាប់។

៧.ជនជាប់ចោទឈ្មោះ [redacted] ស្ងួលីដែត ជានីតិជន ពុំមានភស្តុតាងបញ្ជាក់ថាមានបញ្ហាខាងស្មារតីឡើយ។ជនជាប់ចោទមានស្មារតីល្អ អាចយល់ដឹងពីហេតុ និងបច្ច័យដែលកើតចេញពីអំពើរបស់ខ្លួន។ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

៨.លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុលីដា បានធ្វើសេចក្តីសន្និដ្ឋានថាជនជាប់ចោទឈ្មោះ [redacted] ស្ងួលីដែត ពិតជាបានប្រព្រឹត្តអំពើ ឆបោក ជនរងគ្រោះឈ្មោះ [redacted] សុលីដា ខូចខាតប្រាក់អស់សរុបចំនួនUSD២៨៩,១៧៩ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លារអាមេរិក) ដោយជនជាប់ចោទបានប្រើល្បិចកលទុច្ចរិត លួងលោមជនរងគ្រោះប្រគល់ប្រាក់មកឲ្យដើម្បីរៀបចំធ្វើកិច្ចជំនឿផ្លូវក្នុង ដោយក្ដីខ្លួនបានជឿទុកចិត្តជនជាប់ចោទ ទើបប្រគល់ប្រាក់ទៅឲ្យជនជាប់ចោទ។ ហេតុនេះសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទ និងទាមទារសំណងខូចខាតចំនួនUSD២៨៩,១៧៩ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លារអាមេរិក) និងសំណងជម្ងឺចិត្ត ខូចខាតពេលវេលាចំនួនUSD ១០០,០០០(ដប់ម៉ឺនដុល្លារងាមេរិក) ។

៩.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ជនជាប់ចោទពិតបានប្រព្រឹត្តអំពើ **ឆបោក** ដែលចម្លើយរបស់ជនជាប់ចោទ,ដើមបណ្តឹងរដ្ឋប្បវេណី,ចម្លើយសាក្សី និងឯកសារភស្តុតាងមានភាពស៊ីសង្វាក់គ្នា ហេតុនេះតំណាងអយ្យការនៅ



Scanned with CamScanner

តែតំកល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៧៩ អ.យឧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដដែល និង ស្នើសុំទៅក្រុមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការត្រឹមត្រូវ តុលាការទទួលយកមកពិចារណា។

១០.លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សូលីដែត បានធ្វើសេចក្តីសន្និដ្ឋានថា៖ យោងតាមការបកស្រាយនូវអង្គហេតុខាងលើ បានបញ្ជាក់ផងដែលថាចំពោះបទល្មើស **ឆបោក** ទៅលើជនរងគ្រោះឈ្មោះ [redacted] **សុលីដា** ដែលកូនក្តីខ្លួនឈ្មោះ [redacted] **សូលីដែត** បានប្រព្រឹត្តនោះ កូនក្តីខ្លួនក៏បានសហការផ្តល់ចម្លើយនៅគ្រប់ដំណាក់ការទាំងអស់របស់តុលាការ។ ដោយហេតុថាកូនក្តីខ្លួនមានជីវភាពខ្វះខាតយ៉ាងខ្លាំង ទើបកូនក្តីខ្លួនបង្ខំចិត្តប្រព្រឹត្តនូវអំពើបែបនេះ ហើយកូនក្តីខ្លួនក៏បានដឹងនូវកំហុសរបស់ខ្លួន ដោយមានការសោកស្តាយយ៉ាងខ្លាំង ដែលខ្លួនបានប្រព្រឹត្តអំពើល្មើសនេះ ដោយខ្វះការយល់ដឹង និងមិនបានគិតពិចារណា។ ក៏ប៉ុន្តែ កូនក្តីខ្លួនមិនយល់ស្រប តាមការលើកឡើងពីឈ្មោះ [redacted] **សុលីដា** ថាបានប្រគល់ប្រាក់ឱ្យមកកូនក្តីខ្លួនចំនួន **២៨៩,១៧៩$** (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លាអាមេរិក) គឺមិនមានភាពត្រឹមត្រូវនោះទេ ដោយកូនក្តីខ្លួនបានឆ្លើយបំភ្លឺនៅពេលសវនាការគឺបានអះអាងថាខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] **សុលីដា** ត្រឹមតែ **២០០,០០០$** (ម្ភៃម៉ឺនដុល្លាអាមេរិកអាមេរិក)តែប៉ុណ្ណោះ។ ដោយស្របទៅតាមមាត្រា ៣៧៧ បទឆបោក, មាត្រា ៩៣ និយមន័យនៃស្ថានសម្រាលទោស នៃក្រមព្រហ្មទណ្ឌរបស់ ព្រះរាជាណាចក្រកម្ពុជា។ដោយយោងទៅតាមអង្គហេតុ និងអង្គច្បាប់មានភាពស៊ីចង្វាក់គ្នា ដោយហេតុថាកូនក្តីខ្លួនបានដឹងនូវកំហុសរបស់ខ្លួន ព្រមទាំងមានការសោកស្តាយនូវទង្វើដែលខ្លួនបានប្រព្រឹត្តិ។ បច្ចុប្បន្នស្ថានភាពគ្រួសាររបស់កូនក្តីខ្លួនកំពុងជួបការលំបាក ដែលមានតួនាទីត្រូវប្រកបរបរចិញ្ចឹមគ្រួសារ ដោយមានកូនតូចនៅក្នុងបន្ទុកថែមទៀតផង។ ដូច្នេះខ្លួន សូមឱ្យតុលាការ មេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនឈ្មោះ [redacted] **សូលីដែត** ដោយហេតុថាកូនក្តីរបស់ខ្លួនពិតជាបានទទួលស្គាល់កំហុសរបស់ខ្លួន ហេតុនេះសូមតុលាការមេត្តាពិចារណា ចំពោះស្ថានសម្រាលទោសឱ្យកូនក្តីខ្លួនក្នុងកម្រិតអប្បបរមានៃទោស តាមច្បាប់។

១១.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សូលីដែត** ភេទស្រី កើតថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៣ (អត្តសញ្ញាណដូចខាងលើ) ពីបទ: **ឆបោក** ប្រព្រឹត្តផ្ទះលេខ២៤បេ(បុរីសូនី) ផ្លូវលេខ៩៩ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២១ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។តុលាការគប្បីប្រកាសទោសតាមច្បាប់បញ្ញាត្តិស្របតាមមាត្រា ៣៥០ ក្រមនីតិវិធីព្រហ្មទណ្ឌ។

១២.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុលីដា នៅចំពោះមុខសវនាការបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមមាត្រា ៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការទទួលយកបាន។ ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារសំណងខូចខាតចំនួន ២៨៩,១៧៩$ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លារអាមេរិក) មានភស្តុតាងត្រឹមត្រូវ គប្បីសម្រេចឱ្យតាមការទាមទារ។ចំពោះសំណងជម្ងឺចិត្តដែលទាមទារចំនួន ១០០ ០០០(ដប់ម៉ឺន)ដុល្លារអាមេរិក នោះឃើញថាមានចំនួនច្រើនហួស គប្បីតុលាការសម្រេចឱ្យបានសមរម្យ។

<u>**ហេតុដូច្នេះសម្រេច**</u>

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សូលីដែត** ភេទស្រី កើតថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៣ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ **០២ (ពីរ)ឆ្នាំ** ។



Scanned with CamScanner

ពីបទ៖ **ឆបោក** ប្រព្រឹត្តផ្ទះលេខ២៤បេ(បុរីស្វនី) ផ្លូវលេខ៩៩ ភូមិឬស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២១ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២.ឲ្យឈ្មោះ [redacted] **សូលីដែត** សងសំណងការខូចខាតចំនួនUSD២៨៩,១៧៩ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់មួយរយចិតសិបប្រាំបួនដុល្លារអាមេរិក) និងសំណងជំងឺចិត្តចំនួន ១៦,០០០,០០០(ដប់ប្រាំមួយលាន)រៀល ទៅឲ្យឈ្មោះ [redacted] សុលីដា ជាដើមបណ្តឹងរដ្ឋប្បវេណី ការប្តឹងសុំលើសពីនេះច្រានចោល។

៣.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សូលីដែត,ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុលីដា ។

ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និង ត្រា ៖ [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និង ត្រា ៖ [redacted]

---

**បានឃើញ**
**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner